## មិត្តអាក្រក់ មិត្តល្អ *(ពាក្យ ៧)*

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**

**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ**

*បុគ្គលពុំគួរសេពគប់មិត្រ ចិត្តបាបទុច្ចរិតអាក្រក់ក្រៃ*
*បុរសអធមឥតតម្លៃ លាមកចង្រៃកុំសេពគប់ ។*
*គួរសេពតែមិត្រកល្យាណ មានចិត្តក្សេមក្សាន្តឥតឧបទ្រព្យ*
*បុរសឧត្តមសមទាំងគ្រប់ គួរតែសេពគប់កុំបោះបង់ ។*
*គប់ពាលពាលនាំទៅរកខុស គប់ប្រាជ្ញជាប្រុសកាន់ពេញអង្គ*
*ឬស្រីដែលមានចិត្តផ្ចិតផ្ចង់ ស្លូតត្រង់នាំត្រង់មករកត្រូវ ។*
*វីការសេពគប់នេះតែងឆ្លង ទោះឥតបំណងឲ្យខុសផ្លូវ*
*ក៏តែជិតដោយតាមគ្នាទៅ ពុំបាននៅតាមធម្មតាឡើយ ។*
*មនុស្សឃ្វាលសេះឥតខ្ចុកសោះ សេះបោះជំហានតាមរឿយៗ*
*ដោយវាហាត់តាមពុំកន្តើយ ពុំឃ្លួរលង់ឡើយសេះខ្ចុកដែរ ។*
*ព្រោះវាហាត់ធ្វើតាមគង្វាល ដាលរាលឲ្យចិត្តវាងាកបែរ*
*វាដើរប៉ាក់ពើកប៉ាក់ពើកដែរ ព្រោះតែយល់ថាគេបង្ហាត់ ។*
*ទោះបីជាតិឈើជាតិលតា វាសេពគប់គ្នាត្រាតែកាត់-*
*ឆ្លងតាមគ្នាវាមិនបាច់ហាត់ វែងបាត់ភាពដើមខ្លះពុំខាន ។*
*ជាតិល្វីងលាយគ្នានឹងជាតិផ្អែម ធ្វើជាបង្អែមប្រើការបាន*
*ព្រោះការសេពគប់អាចរុញច្រាន ភាពដើមប៉ុន្មានឲ្យប្រែក្លាម ៕*

# ពឹងខ្លួនឯង *(បទពាក្យ ៧)*

**អត្តា  ហិ  អត្តនោ  នាថោ　　កោ  ហិ  នាថោ  បរោ  សិយា**

**អត្តនា  ហិ  សុទន្តេន　　នាថំ  លភតិ  ទុល្លភំ ។ល។**

*ត្រូវយកខ្លួនយើងជាពំនឹង　　យើងមិនត្រូវពឹងជនណា ៗ*
*ប្រៀបខ្លួនឲ្យល្អក្រអស្ចារ្យ　　បានជាពំនឹងដ៏ក្រក្រី ។*
*បាបដែលខ្លួនឯងបានធ្វើនោះ　　ខ្លួនសម្កពឆ្គោះខ្លួនឯងក្តី*
*បាបញាំញីបានប្រាជ្ញាខ្ចី　　ដូចពេជ្រអាចថ្ងៃកាត់កែវមណី ។*
*វល្លិជ្រៃរសរួបរឹតរាំងភ្នំ　　ជនទ្រុស្តសីលខំញាំងឥន្ទ្រីយ៍*
*ធ្វើឲ្យដួលដូចរាំងគីរី　　ចូលដល់ក្នុងទីមារប៉ុនប៉ង ។*
*កម្មដែលអាក្រក់ងាយធ្វើណាស់　　គ្មានផលល្អច្បាស់ដល់ខ្លួនផង*
*កម្មល្អ ផលល្អក្រកន្លង　　អ្នកផងមិនងាយបានកសាង ។*
*ទុប្បញ្ញវ័ន្តណាមួយក្តី　　អាស្រ័យទិដ្ឋិខុសសព្វយ៉ាង*
*បដិសេធជីវិតដ៏ភ្លឺស្វាង　　នៃខាងអរិយអរហន្តា ។*
*ទស្សនជននោះមានអត្ថន័យ　　ដូចផ្លែឫស្សីជាឧបមា*
*បន្ទាប់ពីបានផលផ្លែផ្កា　　ឫស្សីត្រូវការងាប់ដើមវា ។*
*ធ្វើបាបខ្លួនឯងខ្លួនសៅហ្មង　　មិនធ្វើបាបផងចិត្តខ្លួនថ្លា*
*បរិសុទ្ធសៅហ្មងក្នុងចិន្តា　　គ្មានជនឯណាសំអាតជួស ។*
*បរិសុទ្ធសៅហ្មងប្រាកដជាក់　　ខ្លួនអ្នក អ្នកធ្វើគ្មានជំនួស*
*(សីល សមាធិ បញ្ញា ផ្ទួស)　　មិនអាចធ្វើជួសទេម្ចាស់ថ្លៃ ។*
*ស្គាល់ប្រយោជន៍ខ្លួនប្រសើរក្រៃ　　គប្បីខ្វល់ខ្វាយរូតសន្សំហោង ។៚*

# មិនគួរ

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**

**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិ យា លោកវឌ្ឍនោ ។ល។**

*(បទពាក្យ ៧)*

*មិនគួរសេពគប់ធម៌ថោកទាប មិនសង្គ្រួមភាពប្រមាទធំ*
*មិនគួរទិដ្ឋិយល់ច្រឡំ មិនគួររស់ផ្សំបំព្រៃលោក ។*
*អ្នកបួសកុំមើលងាយភោជន ប្រតិបត្តិធម៌មុនសឹមបរិភោគ*
*ដេកនៅក្នុងធម៌សុខអធ្យោគ នៅក្នុងបរិលោកនិងលោកីយ៍ ។*
*គួរប្រព្រឹត្តធម៌ជាសុចរិត ចៀសវាងទុច្ចរិតកុំមេត្រី*
*អ្នកប្រព្រឹត្តធម៌សុខឥតបី ទោះក្នុងលោកីយ៍លោកខាងមុខ។*
*មច្ចុមិនឃើញនូវជនណា ដែលឃើញសង្ខារថាជាទុក្ខ*
*ដូចពពុះទឹកមានគ្រប់ស្រុក ដូចថ្ងៃបណ្តើរកូនព្រិច ៗ ។*
*មើលលោក (អត្តភាព) ឲ្យប្រាកដ ល្អដូចរាជរថថ្ពៃរលេច*
*ជនពាលជាប់ចិត្តនឹកមិនភ្លេច អ្នកចេះធ្វើកិច្ចមិនជំពាក់ ។*
*ជនណាប្រមាទពីបុព្វេ ក្រោយមកបានរេស្មារតីភ្ញាក់*
*ដូចច័ន្ទរះផុតពពកជាក់ បំភ្លឺលោកអ្នកដោយរស្មី ។*
*កម្មចាស់ជនណាបានលះពិត ដោយកុសលចិត្តថ្នាក់ (អរិយ៍)*
*ដូចច័ន្ទរះផុតនភាល័យ បំភ្លឺលោកីយ៍ត្រជាក់ថ្លា ។*

នរណាអាចឃើញនូវការពិត លោកនេះងងឹតសែនអន្ធការ
ចំនួនតិចណាស់ទៅសួគ៌ា ក្រដូចបក្សារួចលប់ព្រាន ។
ហង្សហើរតាមផ្លូវព្រះអាទិត្យ (អរិយ៍) មានឫទ្ធិអាកាសធ្យាន
បណ្ឌិតចេញចាកលោកបីបាន លោកឈ្មោះមារប្រាណនិងសេនា។
សម្ដីជាឯក គឺសច្ចៈ អស់លក្ខណ៍ដោយប្រើពាក្យមុសា
ឈ្មោះថាកន្លងបរលោកា មានបាបពីណាបើមិនធ្វើ ។
ពាលមិនបានទៅសួគ៌ទេវលោក មកពីកំណាញ់សួគ៌មិនស្មើរ
មិនធ្វើទានហើយមិនសរសើរ ពាលលះដំណើរទាំងពីរហោង ។
បណ្ឌិតធ្វើទានដោយខ្លួនឯង ខ្លះខ្ពែងត្រេកអរទានអ្នកផង
ដល់លោកខាងមុខសុខកន្លង ដោយអានិសង្សអនុមោទនា ។
បានភាពជាធំយ៉ាងស្ដេចចក្រ សោយរាជ្យអនក្សភពភារា
ឬមួយសោយសុខក្នុងសួគ៌ា អ្នកបានសោតាប្រសើរសល់ ៕

